ISSN 1810-6358

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កញ្ញា ២០០៧ / September 2007

ផាន់ ដាលីស / Phann Dalis

ប៉ុន ដូរីណា / Pon Dorina

ហ៊ីង វុត្ថា / Hing Vutha

ភឹម រុនស៊ីណារិទ្ធិ / Phim Runsinarith

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទីពីរ ២០០៧ គំរោងអនុមតិក្នុងវិស័យកាត់ដេរ គឺ ២៤,៣លានដុល្លារ រឺ ធ្លាក់ចុះ ៣៤% ធៀបនឹងត្រីមាសមុន ។ វិស័យកាត់ដេរមានតំលៃស្មើ ១៣% នៃគំរោងវិនិយោគទ្រព្យសកម្មជាប់លាប់សរុបបានអនុម័ត ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ ការអនុមតិក្នុងវិស័យកាត់ដេរធ្លាក់ចុះ ៤៤% ។

In the second quarter 2007, garment sector approvals were USD24.3 m, a decrease of 34 percent from the previous quarter. Garments made up 13 percent of total fixed asset investment approvals. Compared to the same quarter in 2006, garment sector approvals declined by 44 percent.

**Fixed Asset Investment Approvals by CDC for Garment Sub Sector**

2004 Q2–2007 Q2




*Including expansion projects*

Source: Council for the Development of Cambodia

នៅខែមិថុនា ២០០៧ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប ថយចុះ ៤,៤% ធៀបនឹងខែមុន ដល់ ១២៦.៦៧៧នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសមាន ៦៨% នៃភ្ញៀវសរុប ក្នុងនោះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលបាន ៣១% ហើយអាកាសយានដ្ឋានសៀមរាប ទទួលបាន ៣៧% ។ ភ្ញៀវមកដល់ក្នុងបំណងសំរាកលំហែ ធ្លាក់ចុះ ២,៩% ធៀបនឹងខែមុន ប៉ុន្តែធៀបនឹងខែដូចគ្នា ២០០៦ វាកើនឡើង ១៨% ។

Total visitor arrivals to Cambodia decreased by 4.4 percent from the previous month, to 126,677 in June 2007. Visitor arrivals by air made up 68 percent of total arrivals; Phnom Penh international airport received 31 percent of the total arrivals and Siem Reap airport received 37 percent. Arrivals for holiday purposes dropped by 2.9 from the previous month; however, the figure was up by 18 percent from the same month in 2006.

**Cambodia: Foreign Visitor Arrivals**

March 2006–June 2007




Source: Ministry of Tourism

នៅខែមិថុនា ២០០៧ គំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ គឺ ៧៧,៤លានដុល្លារ រឺ កើន ៩,៤% ធៀបនឹងខែមុន ។ ការអនុមតិសំណង់ភូមិគ្រឹះ និងផ្ទះ កើនមួយជាពីរ ធៀបនឹងខែមុន ដល់ ១៤,៨លានដុល្លារ រីឯគំរោងផ្ទះល្វែង ធ្លាក់ចុះ ៦៤% មកត្រឹម ៨,១លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ២០០៦ គំរោងសាងសង់សរុបបានអនុម័ត កើនមួយជាបី ដែលក្នុងនោះគំរោងសំណង់ភូមិគ្រឹះ និងផ្ទះ កើនមួយជាប្រាំ ប៉ុន្តែគំរោងសាងសង់ផ្ទះល្វែង ថយចុះអស់ ៦១% ។

In June 2007, total construction approvals in Phnom Penh were USD77.4 m, an increase of 9.4 percent from the previous month. Villa and house construction approval values doubled from the preceding month to USD14.8 m, while flat approvals dropped by 64 percent to USD8.1 m. Compared to the same month in 2006, there was a threefold increase in total construction approvals; there was a fivefold increase in villa and house construction approvals, but flat construction decreased by 61 percent.

**Phnom Penh: Value of Construction Approvals**

March 2006–June 2007




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ

# Consumer Prices and Interest Rates on Deposits

នៅខែកក្កដា ២០០៧ ថ្លៃទំនិញ និងសេវាទូទៅ កើន ២,២% ធៀបនឹងខែមុន ។ ថ្លៃម្ហូបអាហារកើន ៣,៣% ហើយថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ២,៨% ។ ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ថ្លៃទំនិញប្រើប្រាស់ទាំងអស់ កើន ៦,៥% ថ្លៃម្ហូបអាហារ កើន ១១% ហើយថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ៤,៥% ។

In July 2007, the overall price of goods and services rose by 2.2 percent from the previous month. Food prices increased by 3.3 percent, and transportation and communication costs rose by 2.8 percent. Compared to the same period in 2006, all item prices increased by 6.5 percent; food prices rose by 11 percent, and transportation and communication costs increased by 4.5 percent.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

May 2006–July 2007




Source: National Institute of Statistics

នៅខែសីហា ២០០៧ ថ្លៃសាំង កើន ០,៥% ធៀបនឹងខែមុន ដោយលក់បាន ៣៩៩០រៀល/លីត្រ ។ ថ្លៃម៉ាស៊ូតកើន ១,៥% ដោយលក់បាន ៣២០០រៀល/លីត្រ ។ ទោះជាយ៉ាងនេះក្តី ថ្លៃសាំង និងម៉ាស៊ូត ធ្លាក់ចុះ ៤,៦% និង ៥,២% ធៀបនឹងខែដូចគ្នា ២០០៦ ។

In August 2007, gasoline price rose by 0.5 percent from the previous month, trading at 3990 riels/ℓ. The price of diesel increased by 1.5 percent, selling for 3200 riels/ℓ. However, both gasoline and diesel prices dropped, by 4.6 percent and 5.2 percent respectively, from the same month in 2006.

**Phnom Penh: Gasoline & Diesel Prices**

June 2006–August 2007




Sources: CDRI and National Institute of Statistics

នៅខែមិថុនា ២០០៧ ធនាគារអេស៊ីលីដា និង កាណាឌីយ៉ា មានអត្រាដូចគ្នា គឺ ២៤% លើកំចីជាប្រាក់រៀលក្នុងរយៈ១២ខែ រីឯធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) មានអត្រា ១៨% ។ អត្រាការប្រាក់លើកំចីជាដុល្លារ (១២ខែ) របស់ធនាគារទាំងបី គឺ ១៨% ដូចគ្នា ។ អត្រាការប្រាក់លើកំចីក្នុងរយៈ១២ខែ មិនមានការប្រែប្រួលទេ ចាប់តាំងពីឆ្នាំ២០០៥ ។

In June 2007, ACLEDA Bank and Canadia Bank offered the same rate of 24 percent on twelve month riel loans, while the Foreign Trade Bank (FTB) asked for 18 percent. The interest rate on dollar loans (twelve months) quoted from the three banks was the equal rate of 18 percent. Twelve month loan interest rates have remained unchanged since 2005.

**Interest Rates on 12-Month Bank Loans**

(As of June 2007)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែសីហា ២០០៧ តំលៃប្រាក់រៀលនៅដដែល ទល់នឹងដុល្លារUS ដោយប្តូរបាន ៤០៨៣រៀល/ដុល្លារUS ។ ធៀបនឹងខែដូចគ្នាមួយឆ្នាំមុន ប្រាក់រៀល ឡើងថ្លៃ ១,៤% ។

The riel value was stable against the US dollar in August 2007, trading at 4083 KHR/USD. Compared to the same month in the year earlier, the riel appreciated by 1.4 percent.

**Riels per US Dollar**

June 2006–August 2007




Sources: National Bank of Cambodia and CDRI

ធៀបនឹងខែមិថុនា ២០០៧ ប្រាក់រៀល ឡើងថ្លៃ ១,៧% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១៣០,៤រៀល/បាត នៅខែសីហា ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀល ឡើងថ្លៃ ០,៤% ដោយប្តូរបាន ២៥,៣រៀល/១០០ដុង ។ ធៀបនឹងខែសីហា ២០០៦ ប្រាក់រៀល ធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម អស់ ១៨% និង ១,២% ។

The riel appreciated by 1.7 percent against the Thai baht, compared to July, changing at 130.4 KHR/THB in August 2007. Against the Vietnamese dong, riel appreciated by 0.4 percent, trading at 25.3 KHR per VND 100. The riel value depreciated against Thai baht and Vietnamese dong by 18 percent and 1.2 percent respectively, compared to August 2006.

**Riels per THB & VND**

June 2006–August 2007




Source: CDRI

នៅឆ្នាំ២០០៦ កម្ពុជាទទួលបានការបើកផ្តល់ថវិកាចំនួន ៥៩៤,៨លានដុល្លារ ។ ក្នុងនោះ ភ្នាក់ងារអង្គការសហប្រជាជាតិ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFIs) បានផ្តល់ប្រាក់ ២៧% នៃប្រាក់ដែលបើកផ្តល់សរុប សហគមន៍អឺរ៉ុប (EU) ២៤% អ្នកផ្តល់ជំនួយទ្វេភាគីចំបងៗ ៤១% និង ថវិកាស្នូលពីអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ៨,៤% ។ វិស័យអភិវឌ្ឍន៍ចំបងៗចំនួន ២០ បានប្រើប្រាស់មួយភាគធំនៃជំនួយថវិកាសរុបនេះ រួមទាំងវិស័យសុខាភិបាល និងវិស័យអប់រំ ផងដែរ ។

Cambodia received fund allocations of USD594.8 m in 2006. UN Agencies and International Financial Institutions (IFIs) allocated 27 percent of the total disbursement, the European Union (EU) 24 percent, major bilateral donors 41 percent and core funds from other NGOs, 8.4 percent. Twenty major development sectors shared most of the total assistance disbursement, including health and education sectors.

**External Development Assistance Disbursement: Development Partner Disbursement**

2006




Source: CDC, Cambodia Aid Effectiveness Report 2007

# ការអភិវឌ្ឍន៍រូបិយវត្ថុ
# Monetary Developments

នៅខែមិថុនា ២០០៧ រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ១១០% ហើយការផ្គត់ផ្គង់រូបិយវត្ថុ (M1) ថយចុះតាមអត្រាប្រចាំឆ្នាំ ១១% ។ ក្នុងរយៈ១២ខែ រូបិយវត្ថុទូទៅ (M2) កើន ៤៧% ធៀបនឹងកំណើន ៤០% ក្នុងរយៈ១ឆ្នាំ ដល់ខែឧសភា ២០០៧។

Liquidity (M2) grew at an annualised rate of 110 percent and money supply (M1) fell at an annualised rate of 11 percent in June 2007. Over the preceding 12 months, M2 grew by 47 percent, compared to growth of 40 percent in the year to May 2007.

### Monetary Survey
April 2006–June 2007




Source: National Bank of Cambodia

នៅខែមិថុនា ២០០៧ ឥណទានក្នុងស្រុកកើនតាមអត្រាប្រចាំឆ្នាំ ៧៨% ហើយឥណទានក្នុងវិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៧៤% ។ ក្នុងរយៈ១២ខែ ដល់ខែមិថុនា ឥណទានក្នុងស្រុក កើន ៤៥% ធៀបនឹងកំណើន ៤២% ក្នុងរយៈមួយឆ្នាំ ដល់ខែឧសភា ២០០៧ ។

Domestic credit increased at an annualised rate of 78 percent and private sector credit grew at an annualised rate of 74 percent in June 2007. Over the 12 months to June, domestic credit grew by 45 percent, compared to 42 percent in the year to May 2007.

### Domestic Credit
April 2006–June 2007




Source: National Bank of Cambodia

នៅខែមិថុនា ២០០៧ ឥណទានក្នុងវិស័យឯកជន កើន ៤,៧% ធៀបនឹងខែមុន ដល់ ៤៥៣៨,៧ពាន់លានរៀល ហើយទ្រព្យសកម្មបរទេសសុទ្ធ (NFA) កើន ៥,៥% ដល់ ៩០៤៧,៩ពាន់លានរៀល ។ ឥណទានរដ្ឋាភិបាល ធ្លាក់ចុះ ០,០៤% មកត្រឹម ២៩៧,៦ពាន់លានរៀល រីឯបញ្ញើរដ្ឋាភិបាល កើន ៣,៥% ដល់ ១៧០០,២ពាន់លានរៀល ។ ក្នុងពេលជាមួយគ្នា "បំណុលផ្សេងៗ" កើនឡើង ២,៦% ដល់ ៣៣០៧,៨ពាន់លានរៀល ។ បំរែបំរួលក្នុងប្រតិបត្តិការទាំងនេះ បង្កើនរូបិយវត្ថុទូទៅ ៦,៤% ដល់ ៨៨៧៦,១ពាន់លានរៀល ។

In June 2007, private sector credit rose by 4.7 percent from the preceding month to KHR4538.7 bn, and net foreign assets (NFA) rose by 5.5 percent to KHR9047.9 bn. Government credit fell by 0.04 percent to KHR297.6 bn, while government deposits increased by 3.5 percent to KHR1700.2 bn. At the same time, "other items" worsened by 2.6 percent to KHR3307.8 bn. The net changes in these items increased liquidity by 6.4 percent to KHR8876.1 bn.

### Changes in Monetary Assets
April 2006–June 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅខែមិថុនា ២០០៧ ការនាំចេញសរុបរបស់កម្ពុជា កើនឡើង ៤៥% ធៀបនឹងខែមុន ដល់ ៣១៨,៦លានដុល្លារ ។ ការនាំចេញវិស័យកាត់ដេរ កើន ៤៦% ដល់ ៣១១,១លានដុល្លារ កៅស៊ូ ១៥% ដល់ ៣,៥លានដុល្លារ និងការនាំចេញត្រី កើនឡើងមួយជាបី ធៀបនឹងខែមុន ។ ធៀបនឹងខែមិថុនា ២០០៦ ការនាំចេញសរុប កើន ៤,៦% វិស័យកាត់ដេរ កើន ៤,៥% កៅស៊ូកើន ២,៣% ប៉ុន្តែ ការនាំចេញត្រី បែរជាធ្លាក់ចុះអស់ ៨,២% ។

Cambodia's total exports went up by 45 percent from the previous month to USD318.6 m in June 2007. Garment exports rose by 46 percent to USD311.1 m, rubber, 15 percent to USD3.5 m and fish exports increased by three times the value of the preceding quarter. Total exports rose by 4.6 percent from June 2006; garments increased by 4.5 percent, rubber exports rose by 2.3 percent, while fish exports fell by 8.2 percent.

**Cambodia: Main Exports**
**April 2006–June 2007**




Source: *Monthly Bulletin of Statistics, MEF website*

នៅខែមិថុនា ២០០៧ ការនាំចូលបារី គឺ ៤៦,៨ពាន់លានរៀល រឺ កើន ១៤% ធៀបនឹងខែមុន ។ ការនាំចូលដែក កើន ៨,៧% ដល់ ១៥,៥ពាន់លានរៀល រីឯការនាំចូលស៊ីម៉ង់ត៍ ថយចុះ ១៧% មកត្រឹម ១៥,០ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ២០០៦ ការនាំចូលបារី និងស៊ីម៉ង់ត៍ ធ្លាក់ចុះ ៤,០% និង ២៤% រីឯការនាំចូលដែក កើន ២៩% ។

The imports of cigarettes in June 2007 were KHR46.8 bn, an increase of 14 percent from the previous month. Steel imports also rose by 8.7 percent to KHR15.5 bn, while cement imports decreased by 17 percent to KHR15.0 bn. Compared to the same month in 2006, cigarette and cement imports dropped by 4.0 percent and 24 percent respectively, while steel imports increased by 29 percent.

**Imports: Cigarettes & Construction Material**
April 2006–June 2007




Source: *Monthly Bulletin of Statistics, MEF website*

នៅខែមិថុនា ២០០៧ កម្ពុជាបាននាំចូលសាំង ២២.៧២៥តោន (២៨,៦ពាន់លានរៀល) និង ម៉ាស៊ូត ៤៣.១៣៦តោន (៤៦,៩ពាន់លានរៀល) ។ ការនាំចូលសាំង ថយចុះ ០,២% និង ម៉ាស៊ូត ថយចុះ ៥,៣% ។ ប៉ុន្តែ ធៀបនឹងខែដូចគ្នា ២០០៦ ការនាំចូលសាំង និងម៉ាស៊ូត កើន ៥០% និង ៣៣% ។

In June 2007, Cambodia imported 22,725 tonnes (KHR28.6 bn) of gasoline and 43,136 tonnes (KHR46.9 bn) of diesel. The volume of gasoline imports decreased by 0.2 percent, and diesel imports decreased by 5.3 percent. The volume of gasoline and diesel imports both increased, by 50 percent and 33 percent respectively, from the same month in 2006.

**Imports: Petroleum Products**
April 2006–June 2007




Source: *Monthly Bulletin of Statistics, MEF website*

# ការអនុវត្តន៍ថវិកាជាតិ
# National Budget Operations

នៅខែមីនា ២០០៧ អតិរេកថវិកាចរន្ត គឺ ១០៦,០ពាន់លានរៀល រឺ ថយចុះ ១១% ធៀបនឹងខែមុន ។ អតិរេកនេះកើនមួយជាបី ធៀបនឹង អតិរេក នៅខែមីនា ២០០៦ ។

The current budget surplus in March 2007 was KHR106.0 bn; an 11 percent decrease from the preceding month. The surplus was three time its March 2006 value.

**Current Budget Operations**
October 2005–March 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics, MEF website*

នៅខែមីនា ២០០៧ ចំណូលចរន្តសរុប កើន ៥៣% ធៀបនឹងខែមុន ដល់ ៣៨៥,៧ពាន់លានរៀល ។ ពន្ធក្នុងស្រុកដែលជាប្រភពចំណូលសំខាន់ កើន ៧៦% ដល់ ២៦០,៨ពាន់លានរៀល ចំណូលមិនមែនពន្ធ កើន ៤៨% ដល់ ៥៣,៤ពាន់លានរៀល ហើយពន្ធនាំចេញនាំចូល កើន ៤,៥% ដល់ ៧១,៥ពាន់លានរៀល ។

Total current revenue in March 2007 increased by 53 percent from the previous month, to KHR385.7 bn. Domestic tax, which is the main revenue source, rose by 76 percent to KHR260.8 bn, non tax revenue collections increased by 48 percent to KHR53.4 bn, and import and export taxes rose by 4.5 percent to KHR71.5 bn.

**Current Budget Revenue**
October 2005–March 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics, MEF website*

នៅខែមីនា ២០០៧ ចំណាយចរន្ត ធ្លាក់ចុះ ១៨% ធៀបនឹងខែមុន មកត្រឹម ២០៨,៤ពាន់លានរៀល ។ ចំណាយលើប្រាក់បៀវត្សរ៍ កើន ៦០% ដល់ ១១៤,៧ពាន់លានរៀល ហើយឧបត្ថម្ភធន និងជំនួយសង្គម កើន ៧៨% ដល់ ៣៧,០ពាន់លានរៀល ។ ចំណាយលើសេវាដទៃទៀត ធ្លាក់ចុះ ៦៥% មកត្រឹម ៥៦,៧ពាន់លានរៀល ។ ធៀបនឹងតំលៃនៅខែដូចគ្នា ២០០៦ ចំណាយថវិកា កើន ១៦% ។

In March 2007, current expenditure fell by 18 percent from the month before to KHR208.4 bn. Spending on wages rose by 60 percent to KHR114.7 bn, and subsidy and social assistance increased by 78 percent to KHR37.0 bn. Other services expenditure fell by 65 percent to KHR56.7 bn. Compared with the value in the same month in 2006, budget expenditure rose by 16 percent.

**Current Budget Expenditure Components**
December 2005–March 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics, MEF website*

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា
# Economic Activity of Selected Economic Partners of Cambodia

នៅខែមិថុនា ការនាំចេញទំនិញរបស់ US កើនឡើង រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុនថយចុះ ។ ការនាំចេញទំនិញរបស់ US កើន ២.០% ធៀបនឹងខែមុន ដល់៩៥.១៩ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុន ថយចុះ ០.៣៨% និង ០.៤% ធៀបនឹងខែមុន មកត្រឹម ១៦៧.២០ពាន់លានដុល្លារ និង ៥៧.៥០ពាន់លានដុល្លារ ។

In June, US goods exports increased, while goods exports of the Euro zone and Japan decreased. US goods exports rose by 2.0 percent from the previous month to USD95.19 bn. Goods exports of the Euro zone and Japan decreased by 0.38 percent and 0.4 percent from last month to USD167.20 bn and USD57.50 bn. respectively.

**Goods Exports: US, Euro zone & Japan**
June 2006–June 2007




Sources: BEA, Eurostat and JETRO

នៅខែមិថុនា ចិនមានអតិរេកពាណិជ្ជកម្ម ២៦.៩៤ពាន់លានដុល្លារ ធៀបនឹងអតិរេក ២២.៤៨ពាន់លានដុល្លារ នៅខែឧសភា ។ ការនាំចេញសរុប កើន ៩.៨% ធៀបនឹងខែមុន ដល់ ១០៣.២៧ពាន់លានដុល្លារ រីឯការនាំចូលសរុប កើនយឺតជាងខែមុន គឺ ៦.៦% ដល់ ៧៦.៣៣ពាន់លានដុល្លារ ។

In June, China recorded a trade surplus of USD26.94 bn, compared to USD22.48 bn in May. Total exports rose by 9.8 percent from the previous month to USD103.27 bn, while total imports increased more slowly, by 6.6 percent, to USD76.33 bn.

**External Trade: China**
June 2006–June 2007




Source: National Bureau of Statistics of China

នៅខែមិថុនា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២.៥២ពាន់លានដុល្លារ ធៀបនឹងអតិរេក ២.៣២ពាន់លានដុល្លារ នៅខែឧសភា ។ ទាំងការនាំចេញ និងនាំចូល ថយចុះបន្តិចបន្តួច ធៀបនឹងខែមុន ។ នៅខែមិថុនា ការនាំចេញមាន ១៤.១៨ពាន់លានដុល្លារ ធៀបនឹង ១៤.៥៨ពាន់លានដុល្លារ នៅខែឧសភា ។ ការនាំចូលមាន ១១.៦៦ពាន់លានដុល្លារ ធៀបនឹង ១២.២៦ពាន់លានដុល្លារ នៅខែឧសភា ។

In June, Malaysia recorded a trade surplus of USD2.52 bn, compared to USD2.32 bn in May. Both exports and imports showed modest decreases from the previous month. Exports in June were USD14.18 bn, down from USD14.58 bn. in May. Imports were USD11.66 bn., compared to USD12.26 bn. in May.

**External Trade: Malaysia**
June 2006–June 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅUS កើន ២,៧% នៅរយៈមួយឆ្នាំដល់ខែមិថុនា ។ យោងតាមក្រសួងការងាររបស់US កំណើននេះបណ្តាលជាសំខាន់មកពី ការឡើងថ្លៃម្ហូបអាហារ ការស្នាក់នៅ ការថែទាំសុខភាព និងថាមពល ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាមាន ១,៩% នៅតំបន់អឺរ៉ូ និង-0,២% នៅជប៉ុន ។

US consumer prices increased by 2.7 percent in the year to June. According to the U.S Department of Labor, this increase largely reflected higher charges for food, housing, medical care and energy. The inflation rate for the same period was 1.9 percent in the Euro zone and -0.2 percent in Japan.

### Inflation Rate: US, Euro zone & Japan

(change from a year ago)




*Note: The latest data available are for June 2007*
Sources: IMF and *The Economist* (Aug. 18th 2007)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុងកើន ១,៣% នៅរយៈមួយឆ្នាំដល់ខែមិថុនា ២០០៧ រឺ ខ្ពស់ជាងកំណើន ១,២% នៅខែមុន ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង កើន ៤,៤% និង ២,៥% ។

Hong Kong's consumer prices rose by 1.3 percent in the year to June 2007, higher than the 1.2 percent increase of a month earlier. During the same period, consumer prices in both China and South Korea increased by 4.4 percent and 2.5 percent respectively.

### Inflation Rate: China, Hong Kong & South Korea

(change from a year ago)




*Note: The latest data available are for June 2007*
Sources: IMF and *The Economist* (Aug. 18th 2007)

នៅខែមិថុនា ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីមាន ១,៣% ខ្ពស់ជាងខែដូចគ្នាមួយឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពី ការឡើងថ្លៃម្ហូបអាហារ ការដឹកជញ្ជូននិងទូរគមនាគមន៏ ការថែទាំសុខភាព និងការសំរាកលំហែ ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណានៅរយៈមួយឆ្នាំមាន ១,៤% នៅម៉ាឡេស៊ី និង ១,៩% នៅថៃ ។

Singapore's consumer price index in June 2007 was 1.3 percent higher than for the same month in the previous year. The Department of Statistics of Singapore attributed this to higher costs for food, transport and communication, healthcare, and recreation. During the same period, the year-on-year inflation rate was 1.4 percent in Malaysia and 1.9 percent in Thailand.

### Inflation Rate: Selected ASEAN Countries

(change from a year ago)




*Note: The latest data available are for June 2007*
Sources: IMF and *The Economist* (Aug. 18th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែសីហា ២០០៧ ប្រាក់ដុល្លារUS ឡើងថ្លៃទល់នឹងរូបិយវត្ថុធំបងៗ លើកលែងប្រាក់យ៉េនជប៉ុន ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៣អឺរ៉ូ/ដុល្លារUS រឺឡើងថ្លៃ ០,៧% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៦,៧យ៉េន/ដុល្លារUS រឺធ្លាក់ថ្លៃ ៣,៩% ធៀបនឹងខែមុន ។ ការធ្លាក់ថ្លៃដុល្លារUS បណ្តាលមកពីមានការព្រួយបារម្ភថា ការបាត់បង់កំចីធុនល្អលេខ២នៅUS នឹងធ្វើឱ្យទីផ្សារឥណទានសាកលចុះខ្សោយ ហេតុនេះវានាំឱ្យពាណិជ្ជករសងកំចីជាប្រាក់យ៉េនដែលបានខ្ចីសំរាប់ធ្វើវិនិយោគ ។

In August 2007, the US dollar advanced against most major currencies except the Japanese yen. Against the euro, it traded at 0.73 EUR/USD, a 0.7 percent gain from a month earlier. Against the Japanese yen, it exchanged at 116.7 JPY/USD, a 3.9 depreciation from June 2007. This was due to the concern that U.S. sub-prime mortgage losses are weakening global credit markets, prompting traders to repay yen loans used to fund investments.

**EUR & JPY Per USD**
Aug 06–Aug 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែសីហា ២០០៧ ទល់នឹងដុល្លារUS ប្រាក់វ៉ុនកូរ៉េខាងត្បូងប្តូរបាន ៩៣៤,៤៩វ៉ុន/ដុល្លារUS រឺធ្លាក់ថ្លៃ ១,៨% ធៀបនឹងខែកក្កដា ។ ប្រាក់វ៉ុនធ្លាក់ថ្លៃ នៅពេលការបាត់បង់កំចីធុនល្អលេខ២នៅUS ជះឥទ្ធិពលដល់ទីផ្សារឥណទាន ដែលធ្វើឱ្យវិនិយោគិនងាកចេញពីទីផ្សារអចលនទ្រព្យ ។ ក្នុងអំឡុងពេលដូចគ្នា ដុល្លារហុងកុងមិនប្រែប្រួលទេ ទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៨២ដុល្លារហុងកុង/ដុល្លារUS ។

In August 2007, the South Korean won exchanged at 934.49 KRW/USD against the US dollar, 1.8 percent depreciation from July 2007. The won weakened as U.S. sub-prime mortgage losses spread to credit markets, prompting investors to steer away from emerging-market assets. During the same period, the Hong Kong dollar remained steady against its US counterpart, trading at 7.82 HKD/USD.

**KRW & HKD Per USD**
Aug 06–Aug 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែសីហា ២០០៧ ដុល្លារសិង្ហបុរីធ្លាក់ថ្លៃ ទល់នឹងដុល្លារUS ដោយប្តូរបាន ១,៥២៣ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹងអត្រា ១,៥១៦ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែមុន ។ ទល់នឹងដុល្លារUS ប្រាក់បាតថៃក៏ធ្លាក់ថ្លៃដែរ ដោយប្តូរបាន៣១,៨០បាត/ដុល្លារUS រឺធ្លាក់ថ្លៃ ៤,៤% ធៀបនឹងខែកក្កដា ។ រូបិយវត្ថុនៅអាស៊ីធ្លាក់ថ្លៃ ដោយសារការវាយស្មានថា ការធ្លាក់ចុះតំរូវការផ្ទះស្នាក់នៅក្នុងសហរដ្ឋអាមេរិក នឹងពន្យឺតដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសនោះ ដែលអាចកាត់បន្ថយតំរូវការនាំចេញរបស់តំបន់អាស៊ី ។

In August 2007, the Singapore dollar lost value against the US dollar, traded at 1.523 SGD/USD compared to 1.516 SGD/USD a month earlier. The Thai baht also depreciated against the US dollar, exchanging at 31.80 THB/USD, a 4.4 percent fall from July 2007. Asian currencies declined on speculation that the U.S. housing slump will slow the world's biggest economy, crimping demand for the region's exports.

**THB & SGD Per USD**
Aug 06–Aug 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែកក្កដា ថ្លៃអង្ករពិភពលោក កើនឡើងដោយសារមានតំរូវការនាំចូលខ្ពស់ និងការផ្គត់ផ្គង់ការនាំចេញមានតិចតួច ។ សន្ទស្សន៍ថ្លៃទំនិញអន្តរជាតិ (IPO) មាន ១៤០,៨ពិន្ទុ ខ្ពស់ជាង ១៣៩,៦ពិន្ទុ នៅខែមិថុនា ។ នៅថៃ ថ្លៃអង្ករថៃ100%B កើន ១,៥% ធៀបនឹងខែមុន ដល់ ៣០៩,២៩ដុល្លារUS/តោន ។ នៅUS ថ្លៃអង្ករនាំចេញធ្លាក់ចុះ ០,២% ធៀបនឹងខែមុន មកត្រឹម ៣៧១,៨៧ដុល្លារUS/តោន ។

In July, world rice prices increased due to strong import demand and limited export supply. The International Prices Index (IPO) was 140.8, up from 139.6 in June. In Thailand, the price of Thai 100%B rose by 1.5 percent from the previous month to USD309.29 per tonne. In the United States, the export price decreased by 0.2 percent from the previous month to USD371.87 per tonne.

**Rice: International Prices Index & Export Prices**
July 2006–July 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែសីហា សណ្តែកសៀងឡើងថ្លៃ រីឯពោតធ្លាក់ថ្លៃ ។ សណ្តែកសៀងលក់ថ្លៃ ២៨៩,១៤ដុល្លារUS/តោន ធៀបនឹង ២៨៧,១៨ដុល្លារUS/តោន នៅខែកក្កដា ។ ពោតលក់ថ្លៃ ១៣៧,៩៦ដុល្លារUS/តោន រីធ្លាក់ថ្លៃ ០,៣% ធៀបនឹងខែមុន ។ នៅខែកក្កដា ប្រេងឆាឡើងថ្លៃ ០,៧% ធៀបនឹងខែមុន ដល់ ៧៣៥,៥៨ដុល្លារUS/តោន ។

In August, the price of soybeans increased, while the price of maize decreased. Soybeans sold at USD289.14 per tonne, up from USD287.18 per tonne in July. Maize was USD137.96 per tonne, a 0.3 percent decline from the previous month. In July, the price of palm oil increased by 0.7 percent from the previous month to USD735.58 per tonne.

**Prices: Soybeans, Maize & Palm Oil**
August 2006–August 2007




Source: Food and Agriculture Organisation (FAO)

នៅខែសីហា ប្រេងឆៅ សាំង និងម៉ាស៊ូត ធ្លាក់ថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៩,៩៦ដុល្លារ/ធុង ធៀបនឹង ៧១,៩៤ ដុល្លារ/ធុង នៅខែកក្កដា ។ នៅ US Gulf Coast ថ្លៃសាំងធម្មតា (អុកតាន ៨៧) ធ្លាក់ចុះ ១៣% ធៀបនឹងខែមុន មកត្រឹម ៥១,៥២សេន/លីត្រ ។ ថ្លៃម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) ធ្លាក់ចុះ ៣,៦% ធៀបនឹងខែមុន មកត្រឹម ៥៤,៥២សេន/លីត្រ ។

In August, the prices of crude oil, gasoline and diesel decreased. The OPEC spot price for crude oil was USD69.96 per barrel, against USD71.94 in July. Regular gasoline (87 octane) prices on the US Gulf Coast declined by 13 percent from the previous month to 51.52 cents per litre. Diesel (low sulphur No.2) on the US Gulf Coast decreased by 3.6 percent from the previous month, to 54.52 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
August 2006–August 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**រដ្ឋាភិបាល និង ធនាគារពិភពលោក បានចុះហត្ថលេខាលើការផ្តល់ជំនួយ :** រាជរដ្ឋាភិបាលកម្ពុជា និង ធនាគារពិភពលោក(WB) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយ ៧០លានដុល្លារ សំរាប់ ៣ គំរោង ដែលថ្មីៗនេះបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៃ WB ។ គំរោងទាំងបី រួមមានៈ គំរោងពាណិជ្ជកម្មថាមពលនៅមហាអនុតំបន់ទន្លេមេគង្គ(GMS) ប្រតិបត្តិការសំរាប់កំនើននិងការកាត់បន្ថយភាពក្រីក្រ(PRGO) និង ការផ្តល់ហិរញ្ញប្បទានបន្ថែមសំរាប់គំរោងវិនិយោគនៅតំបន់ជនបទនិងអភិបាលកិច្ចមូលដ្ឋាន (RILGP-AF) ។ គំរោងទាំងនេះ នឹងជួយដល់កំណែទំរង់ផ្សេងៗ និងមានគោលដៅផ្តល់ទំនិញនិងសេវា ដើម្បីជួយដល់កំណើន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ គំរោងពាណិជ្ជកម្មថាមពលGMS ដែលមានទឹកប្រាក់ ១៨,៥លានដុល្លារ នឹងជួយពង្រីកការធ្វើពាណិជ្ជកម្មថាមពលនៅGMS និងផ្គត់ផ្គង់អគ្គិសនីមានតំលៃសមរម្យដល់កម្ពុជា តាមរយៈការផ្តល់ថវិកាកសាងខ្សែបញ្ជូនអគ្គិសនីតភ្ជាប់ទៅឡាវ និង វៀតណាម ។ គំរោង PRGO ដែលមានទឹកប្រាក់ ១៥លានដុល្លារ ជាប្រតិបត្តិការដំបូងក្នុងចំណោម គំរោងទាំង៣ ដោយផ្តោតលើកម្មវិធីកំណែទំរង់ "អភិបាលកិច្ចល្អ" មាននៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ជាតិរបស់រដ្ឋាភិបាល ២០០៦-២០១០ ។ វាផ្តោតលើវិស័យស្នូល៣ គឺការអភិវឌ្ឍន៏វិស័យឯកជន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងធនធានធម្មជាតិ ។ RILGP-AF មានទឹកប្រាក់ចំនួន ៣៦,២៥លានដុល្លារ និងមានគោលដៅពង្រីកការគាំទ្រគំរោង ដែលបច្ចុប្បនមានពី ១៥-២៣ ខេត្ត/ក្រុង និងផ្តល់ហិរញ្ញវត្ថុបន្តបន្ទាប់សំរាប់រយៈពេល៣ឆ្នាំទៀតពី២០០៧-២០០៩ ដល់យន្តការផ្ទេរសារពើពន្ធរវាងអាជ្ញាធរមូលដ្ឋាន (មូលនិធិឃុំ/សង្កាត់) និង ជួយសំរួលដល់កំណើនទូទៅនៃការផ្ទេរសារពើពន្ធរវាងឃុំ/សង្កាត់ និង ការបែងចែកថវិកាទៅឱ្យឃុំដែលពាក់ព័ន្ធ។

***Government and World Bank Sign Grant:*** The Royal Government of Cambodia and the World Bank signed grant agreements for three projects totaling USD70 m. that were recently approved by the World Bank Board of Executive Directors. The three projects are: the Greater Mekong Sub-region (GMS) Power Trade Project, the Poverty Reduction and Growth Operation (PRGO), and Additional Financing for the Rural Investment and Local Governance Project (RILGP-AF). These projects will support Cambodia's reform efforts and aim to provide goods and services that will help to accelerate growth and reduce poverty in Cambodia. The *GMS Power Trade Project*, a grant of USD18.5 m., will help enhance regional power trade within the GMS and bring more affordable grid-based electricity to Cambodia by financing the construction of cross-border transmission lines to neighboring Lao PDR and Vietnam. The *Poverty Reduction and Growth Operation*, a grant of USD15 m., is the first of three operations that focus on support for the "good governance" reform program laid out in the Government's National Strategic Development Plan (NSDP), 2006–2010. The PRGO focuses on three core areas: private sector development, public financial management, and natural resources management The Additional Financing for the *Rural Investment and Local Governance Project (RILGP)*, a grant of USD36.25 m., aims to expand the project support from the current 15 to 23 provinces and cities, provide continuing financing for an additional three years from 2007–2009 to the intergovernmental fiscal transfer mechanism, the Commune/*Sangkat* Fund, and facilitate an accelerated increase in the amount of the overall intergovernmental fiscal transfer and related commune allocations. *(Cited from World Bank Press Release,14 August 2007)*

**ទេសចរណ៏ក្នុងតំបន់ បានប្រមើលមើលទៅតំបន់មាត់សមុទ្រ :** មន្រ្តីផ្នែកទេសចរណ៏កម្ពុជា ថៃ និងវៀតណាមបានជួបប្រជុំគ្នានៅក្រុងព្រះសីហនុ ដើម្បីពិភាក្សាពីការជំរុញដល់ការអភិវឌ្ឍន៏ទេសចរណ៏ នៅតំបន់មាត់សមុទ្ររួមនៃប្រទេសទាំង៣ ។ លោក ថោង ខុន រដ្ឋមន្រ្តីក្រសួងទេសចរណ៏កម្ពុជាមានប្រសាសន៏ថា ប្រទេសទាំងបី បានព្រមព្រៀងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងគោលដៅបង្វែរតំបន់មាត់សមុទ្ររួម ឱ្យទៅជាតំបន់ទេសចរណ៏មួយដែលទាក់ទាញ ។ របៀបវារៈនៃកិច្ចពិភាក្សា គឺផ្តោតលើការបណ្តុះបណ្តាលធនធានមនុស្សបំរើឱ្យទេសចរណ៏នៅតំបន់មាត់សមុទ្រ ការភ្ជាប់ខ្សែទស្សនៈកិច្ចនៅទីគោលដៅទេសចរណ៏របស់ប្រទេសទាំង៣ និង ការផ្លាស់ប្តូរបទពិសោធន៏និងការគ្រប់គ្រងប្រតិបត្តិការទេសចរណ៏ ។ កិច្ចប្រជុំលើកទី២ គ្រោងនឹងធ្វើឡើងនៅថៃ ក្នុងឆ្នាំ២០០៨ ។

***Regional Tourism Looks to the Sea:*** Tourism officials from Cambodia, Thailand and Vietnam have gathered in a meeting in Cambodia's Sihanoukville to look into ways to boost the development of tourism in the three countries' common sea area. Cambodia's Minister for Tourism, Thong Khon, said after the meeting that participants had agreed upon measures to strengthen cooperation among the three countries in order to turn their common sea area into an attractive tourism destination. High on the agenda of the meeting were discussions on the training of human resources for sea tourism, linkage tours between tourism destinations in the three countries, and the exchange of experience and tour operation management in the tourism sector. The second meeting of its kind is scheduled to take place in Thailand in 2008. *(Cited from VNA/VNS 27 August 2007)*